ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សេចក្តីប្រកាសព័ត៌មាន
# ការចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានហិរញ្ញវត្ថុពាក់ព័ន្ធនឹង ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និង មជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការអូស្ត្រាលី

កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានិង មជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការអូស្ត្រាលី (AUSTRAC) បានចុះហត្ថលេខា លើអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានហិរញ្ញវត្ថុពាក់ព័ន្ធនឹងការប្រឆាំងការ សម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលលើកទីពីរ ស្តីពី ការប្រឆាំងហិរញ្ញប្បទានភេរវកម្មប្រចាំតំបន់ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ដែលមាន សមាជិកចូលរួមចំនួន២៥ប្រទេសរួមទាំងអង្គការអន្តរជាតិជាច្រើន ។

ដោយយល់ឃើញពីអត្ថប្រយោជន៍នៃការរឹតចំណងមិត្តភាពរវាងប្រទេសទាំងពីរ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងមជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការ អូស្ត្រាលី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធ នឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងគោលបំណងពង្រឹងនិងពង្រីក កិច្ចសហប្រតិបត្តិការអន្តរជាតិ នាពេលអនាគត និងកិច្ចខិតខំប្រឹងប្រែងរួម ក្នុងការស្វែងរក ទប់ស្កាត់ និងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ការចុះហត្ថលេខានៅពេលនេះ គឺជាលើកទី១១ ដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ កម្ពុជាបានចុះអនុស្សរណៈនិងកិច្ចព្រមព្រៀងជាមួយភាគីបរទេស ។ នាពេលកន្លងមក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាធ្លាប់ចុះអនុស្សរណៈជាមួយ ប្រទេសម៉ាឡេស៊ី បង់ក្លាដេស ស្រីលង្កា ជប៉ុន សាធារណរដ្ឋកូរ៉េ វៀតណាម ថៃ ឡាវ ឥណ្ឌូណេស៊ី និងសហព័ន្ធរុស្ស៊ី ។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧